ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

GENERAL DEPARTMENT OF TAXATION

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០១៣ ដោយអគ្គនាយកដ្ឋានពន្ធដារ

# សេចក្តីប្រកាសព័ត៌មាន
# អំពី
# ការរៀបចំបើកវគ្គសិក្ខាសាលាស្តីពី
# កំណែទម្រង់រដ្ឋបាលសារពើពន្ធនៅប្រទេសឥណ្ឌូនេស៊ី

នាវេលាម៉ោង 8:30 នាទីព្រឹក ថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៣ នៅអគ្គនាយកដ្ឋានពន្ធដារមានការរៀបចំវគ្គសិក្ខាសាលា ស្តីអំពីកំណែទម្រង់រដ្ឋបាលសារពើពន្ធនៅប្រទេសឥណ្ឌូនេស៊ី (Tax Administration Reform) ដល់មន្ត្រីពន្ធដារកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ហើយមានការចូលរួមថ្នាក់ដឹកនាំនិងមន្ត្រីនៅនាយកដ្ឋានទាំង៧ នៅថ្នាក់កណ្តាល ថ្នាក់ដឹកនាំនិងមន្ត្រីនៅសាខាពន្ធដារខណ្ឌទាំង៧ នៅរាជធានីភ្នំពេញ ក្រុមការងារផ្នែកសវនកម្មពន្ធ និងក្រុមការងារផ្នែកសេវាអ្នកជាប់ពន្ធ សរុបចំនួន ១១៥ នាក់ ចែកចេញជាពីរវគ្គ គឺ នៅថ្ងៃទី១១ -១២ ខែធ្នូ ឆ្នាំ២០១៣ នេះ។

នៅក្នុងអង្គសិក្ខាសាលានេះធ្វើបទបង្ហាញដោយលោក Mr. Wahyu karya និង Dr. Nufransa Wira Sakti ប្រធាននាយកដ្ឋាន និងធ្លាប់បានដឹកនាំកម្មវិធីកំណែទម្រង់រដ្ឋបាលសារពើពន្ធនៅប្រទេសឥណ្ឌូនេស៊ី តាំងពីឆ្នាំ ២00២ មករហូតដល់បច្ចុប្បន្ន។

សិក្ខាសាលានេះមានគោលបំណង ឲ្យមន្ត្រីពន្ធដាររបស់អគ្គនាយកដ្ឋានពន្ធដារបានយល់ពីបទពិសោធន៍ និងស្ថានភាពបច្ចុប្បន្នរបស់រដ្ឋបាលសារពើរពន្ធប្រទេសឥណ្ឌូនេស៊ី។ ដើម្បីជំរុញកិច្ចការងារដំណើរឆ្ពោះទៅរកការអនុវត្តន៍ និងវឌ្ឍនភាពសម្រាប់អគ្គនាយកដ្ឋានពន្ធដារទាំងមូល។ គំនិតផ្តួចផ្តើមសម្រាប់កំណែទម្រង់រដ្ឋបាលសារពើពន្ធឥណ្ឌូនេស៊ី (ជំហានទី1 និងទី2 ការណែនាំទូទៅបទពិសោធន៍ និងបញ្ហាប្រឈម)

- ការផ្លាស់ប្តូរការគ្រប់គ្រង
- ការកែលម្អដំណើរការក្នុងអង្គភាពពន្ធដារ
- ផ្នែកស្នូលនៃការកែលម្អប្រព័ន្ធពន្ធដារ (ការណែនាំទូទៅ បទពិសោធន៍ ជាពិសេស ការចូលរួមរបស់មន្ត្រីចំពោះបញ្ហាប្រឈម និងការប្តេជ្ញាចិត្តរបស់គាត់)
- ការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា

ក្នុងកិច្ចសហប្រតិ្តបត្តិការរវាងអគ្គនាយកដ្ឋានពន្ធដារជាមួយ JICA គម្រោងអភិវឌ្ឍន៍សមត្ថភាពអគ្គនាយកដ្ឋានពន្ធដារ ត្រូវបានចុះហត្ថលេខា កាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១១ រវាងឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយដ្ឋានពន្ធដារ ជាមួយប្រធានតំណាងទីភ្នាក់ងារសហប្រតិ្តបត្តិការអន្តរជាតិជប៉ុនប្រចាំកម្ពុជា ដើម្បីបន្តជួយឧបត្ថម្ភអគ្គនាយកដ្ឋានពន្ធដារ ក្នុងការចូលរួមកំណែទម្រង់សារពើពន្ធ ស្របតាមកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM) ជាពិសេស ដើម្បីបង្កើនចំណូលពន្ធ តាមរយៈការបង្កើនសមត្ថភាពជំនាញដល់មន្ត្រីពន្ធដារ ខាងផ្នែកសវនកម្ម និង សេវាកម្មអ្នកជាប់ពន្ធ និងផ្នែកផ្សេងៗទៀត ។

ជាលទ្ធផលទទួលបានក្រោយពីអនុវត្តគម្រោងចាប់ពី ខែមិថុនា ឆ្នាំ២០១១ រហូតមកដល់បច្ចុប្បន្ន មានដូចជា ៖

- បណ្តុះបណ្តាលមន្ត្រីពន្ធដារ ស្តីអំពីសវនកម្មសារពើពន្ធ លើក្រុមហ៊ុនពហុជាតិ

-វគ្គសិក្ខាសាលាស្តីពី Critical Thinking ជូនថ្នាក់ដឹកនាំ និងមន្ត្រីពន្ធដារនៅអគ្គនាយកដ្ឋានពន្ធដារ

-ថ្នាក់ដឹកនាំនិងមន្ត្រីពន្ធដារមួយចំនួនបានចូលរួមសិក្ខាសាលា ស្តីពីការគ្រប់គ្រងអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស នៅប្រទេសជប៉ុន ប្រទេសម៉ាឡេស៊ុី ប្រទេសឥណ្ឌូនេស៊ុី។

-ថ្នាក់ដឹកនាំនិងមន្ត្រីនៃអគ្គនាយកដ្ឋានពន្ធដារ បានធ្វើទស្សកិច្ចសិក្សាស្តីអំពី Data Processing Center នៅប្រទេសថៃឡង់ដ៍ ប្រទេសសិង្ហបុរី និងប្រទេសម៉ាឡេស៊ី។

-បោះពុម្ពសៀវភៅស្តីអំពី ១) កម្រងបទប្បញ្ញត្តិស្តីអំពី អាករលើតម្លៃបន្ថែមចំនួន ២) កម្រងបទប្បញ្ញត្តិស្តីអំពីពន្ធប្រាក់ចំណេញ និង ៣) បានផ្តល់ឯកសារស្វែងយល់នានា ពាក់ព័ន្ធនឹងសារពើពន្ធ និងគណនេយ្យ ។

ក្នុងអង្គពិធីនោះ **ឯកឧត្តម គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានផ្តាំផ្ញើដល់សិក្ខាកាមទាំងអស់ ត្រូវយកចិត្តទុកដាក់គោរពវិន័យ និងខិតខំប្រឹងប្រែងស្តាប់គ្រូឧទ្ទេសនាមឱ្យបានស៊ីជំម្រៅ បំផុសសំណួររាល់ចម្ងល់ទាំងឡាយ និងក្រេបយកបទពិសោធន៍ល្អៗ ដើម្បីសិក្សាស្វែងយល់ មកអនុវត្តការងារឱ្យមានប្រសិទ្ធិភាពខ្ពស់ ព្រមទាំងថ្លែងអំណរគុណយ៉ាងស្មោះស្ម័គ្រ ចំពោះ៖ លោក Mr. Wahyu karya Tumakaka និងDr. Nufransa Wira Sakti អ្នកជំនាញការមកពីប្រទេសឥណ្ឌូនេស៊ុី ដែលបានខិតខំធ្វើបទបង្ហាញ និងចែករំលែកនូវបទពិសោធន៍ល្អៗនិងមានតម្លៃដល់មន្ត្រីពន្ធដារកម្ពុជា និងលោក លោកស្រី ជាតំណាងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិប្រទេសជប៉ុនប្រចាំកម្ពុជា ដែលបានជួយឧបត្ថម្ភក្នុងគម្រោងអភិវឌ្ឍន៍សមត្ថភាពអគ្គនាយក-ដ្ឋានពន្ធដារ។








